# ព្រះរាជាណាចក្រកម្ពុជា

## ជាតិ សាសនា ព្រះមហាក្សត្រ

## សេចក្ដីសម្រេចកែសម្រួលលើកទី៣

## លើឯកសារអាជ្ញាប័ណ្ណរួមលេខ ០១៣ ឯអ ចុះថ្ងៃទី០៦ ខែកញ្ញា ឆ្នាំ២០០២

## ជាមួយសេចក្ដីសម្រេចកែសម្រួលលើកទី២ លេខ ០៨១ សរ.០៥.អអក

## ចុះថ្ងៃទី០៦ ខែកញ្ញា ឆ្នាំ២០០៥

## សម្រាប់លោក ម៉ាក់ ធន

## អាជ្ញាធរអគ្គិសនីកម្ពុជា

-អនុវត្តតាមមាត្រា ៧ និង ៣៥ របស់ច្បាប់ស្ដីពីអគ្គិសនីនៃព្រះរាជាណាចក្រកម្ពុជា ដែលប្រកាសឱ្យប្រើដោយព្រះរាជក្រមលេខ នស/រកម/០២០១/០៣ ចុះថ្ងៃទី០២ ខែកុម្ភៈ ឆ្នាំ២០០១

-យោងឯកសារអាជ្ញាប័ណ្ណលេខ០១៣ឯអ ចុះថ្ងៃទី០៦ ខែកញ្ញា ឆ្នាំ២០០២

-យោងសេចក្ដីសម្រេចកែសម្រួលលើកទី២ លើឯកសារអាជ្ញាប័ណ្ណរបស់លោក ម៉ាក់ ធន លេខ០៨១ សរ-០៥-អអក ចុះថ្ងៃទី០៦ ខែកញ្ញា ឆ្នាំ២០០៥

-យោងពាក្យស្នើសុំពង្រីកតំបន់ចែកចាយអគ្គិសនីរបស់លោក ម៉ាក់ ធន ចុះថ្ងៃទី០២ ខែកក្កដា ឆ្នាំ២០០៧

-យោងតាមការពិគ្រោះយោបល់ជាមួយអ្នកពាក់ព័ន្ធ និងសាធារណជន ដែលបានធ្វើចាប់ពីថ្ងៃទី០៦ ខែកញ្ញា ឆ្នាំ២០០៧ ដល់ថ្ងៃទី១៥ ខែតុលា ឆ្នាំ២០០៧

-យោងតាមការអនុម័តរបស់សម័យប្រជុំអាជ្ញាធរអគ្គិសនីកម្ពុជា លើកទី១១៥ នៅថ្ងៃទី៣០ ខែវិច្ឆិកា ឆ្នាំ២០០៧

## សម្រេច

### ប្រការ១

កែសម្រួលអាជ្ញាប័ណ្ណលេខ ០១៣ ឯអ ដែលបានផ្ដល់ឱ្យលោក ម៉ាក់ ធន ដោយអនុញ្ញាតឱ្យពង្រីកតំបន់ចែកចាយអគ្គិសនីទៅ២ទីតាំង:

-ទីតាំងទី១ តាមបណ្ដោយផ្លូវជាតិលេខ២ ពីព្រំប្រទល់មានស្រាប់ទៅទល់ព្រំប្រទល់ចែកចាយរបស់អ្នកកាន់អាជ្ញាប័ណ្ណលេខ០១៦ ឯអ ។

-ទីតាំងទី២ ពីព្រំប្រទល់មានស្រាប់ឆ្ពោះទៅភូមិចំនួន៦នៃឃុំត្រពាំងស្រង់ និងឃុំព្រៃរំពក ស្រុកគីរីវង់ ខេត្តតាកែវ ដើម្បីអនុញ្ញាតឱ្យលោក ម៉ាក់ ធន ធ្វើសេវាកម្មផ្គត់ផ្គង់អគ្គិសនីឱ្យអ្នកប្រើប្រាស់បន្ថែម ដូចមានបង្ហាញក្នុងផែនទីភ្ជាប់ក្នុងឧបសម្ព័ន្ធទី១ ។

**ប្រការ២**

ឧបសម្ព័ន្ធទី១ ចាស់នៃអាជ្ញាប័ណ្ណលេខ ០១៣ ឯអ ត្រូវជំនួសដោយឧបសម្ព័ន្ធ ទី១ កែសម្រួលថ្មី ដែលមានភ្ជាប់មកជាមួយ ។

**ប្រការ៣**

សេចក្តីសម្រេចនេះនិងឧបសម្ព័ន្ធកែសម្រួលថ្មីនេះ ត្រូវចាត់ទុកជាផ្នែកមួយនៃឯកសារអាជ្ញាប័ណ្ណលេខ ០១៣ ឯអ។

**ប្រការ៤**

ខ្លឹមសារ និងល័ក្ខខ័ណ្ឌដទៃទៀតនៃឯកសារអាជ្ញាប័ណ្ណលេខ ០១៣ឯអ និងខ្លឹមសារ ដែលបានកែសម្រួលរួចហើយ ត្រូវស្ថិតនៅជាធរមានដដែល ។

**ប្រការ៥**

សេចក្តីសម្រេចនេះ ត្រូវចូលជាធរមានចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។

**ប្រការ៦**

អ្នកកាន់អាជ្ញាប័ណ្ណ ត្រូវផ្ញើរសេចក្តីសម្រេចនេះទៅតម្កល់ទុកបន្ថែមនៅតាម ទីកន្លែងដែលឯកសារអាជ្ញាប័ណ្ណលេខ ០១៣ឯអ បានតម្កល់ទុកពីមុន ដើម្បីឱ្យឯកសារអាជ្ញាប័ណ្ណលេខ ០១៣ឯអ ដែលតម្កល់ទុកមានការកែសម្រួលជាថ្មី ស្របតាមសេចក្តីសម្រេចនេះ ។

ភ្នំពេញ ថ្ងៃទី៣០ ខែវិច្ឆិកា ឆ្នាំ២០០៧

**ប្រធានអាជ្ញាធរអគ្គិសនីកម្ពុជា**

## ឧបសម្ព័ន្ធទី១
## តំបន់អនុញ្ញាតឱ្យចែកចាយអគ្គិសនី
## ធ្វើការកែសម្រួលជាថ្មី ក្នុងសម័យប្រជុំរបស់អាជ្ញាធរអគ្គិសនីកម្ពុជា
## លើកទី ១១៥ នាថ្ងៃទី៣០ ខែវិច្ឆិកា ឆ្នាំ២០០៧

១- តំបន់អនុញ្ញាតឱ្យលោក ម៉ាក់ ធន ធ្វើសេវាកម្មចែកចាយនិងផ្គត់ផ្គង់អគ្គិសនីតាមបណ្ដោយផ្លូវជាតិលេខ២ តំបន់ចាប់ពីព្រំប្រទល់វៀតណាមមករហូតដុតឃុំពេជសារ និងបែកតាមផ្លូវព្រះបាទជាន់ជុំ ទៅឃុំព្រែកអំពក នៅក្នុងស្រុកគីរីវង់ និងស្រុកទ្រាំង ខេត្តតាកែវ។

២- តំបន់អនុញ្ញាតឱ្យចែកចាយអគ្គិសនីនេះ កំណត់ដោយ "ផែនទីកំណត់ព្រំ ប្រទល់លេខ 013LD-map-Mak Thorn -Revised-3-2007" ដែលភ្ជាប់មកជាមួយ។

៣- ក្នុងក្របខ័ណ្ឌនៃអាជ្ញាប័ណ្ណនេះ ប្រសិនបើលោក ម៉ាក់ ធន មានបំណងស្នើសុំពង្រីក ឬបន្ថែមតំបន់ចែកចាយថែមទៀត ពេលនោះលោក ម៉ាក់ ធន ត្រូវរៀបចំឯកសារចាំបាច់នានា ដាក់ស្នើសុំមកអាជ្ញាធរអគ្គិសនីកម្ពុជាតាមការកំណត់របស់អាជ្ញាធរ ។ ក្រោយពេលដែលអាជ្ញាធរអគ្គិសនីកម្ពុជា ចេញសេចក្ដីសម្រេចអនុញ្ញាតឱ្យពង្រីក ឬបន្ថែមតំបន់ចែកចាយណាមួយ ឧបសម្ព័ន្ធទី១នេះ ត្រូវធ្វើការកែសម្រួលដោយភ្ជាប់ជាមួយសេចក្ដីសម្រេចឱ្យពង្រីកបន្ថែមតំបន់ចែកចាយនោះ ។

លក្ខខ័ណ្ឌរបស់អាជ្ញាប័ណ្ណនេះមានខ្លឹមសារដូចអាជ្ញាប័ណ្ណលេខ ០១៥.ឯអ ចុះថ្ងៃទី២២ ខែវិច្ឆិកា ឆ្នាំ២០០២ ។ប្រសិនបើចង់ពិនិត្យមើលខ្លឹមសារ សូមពិនិត្យមើលផ្នែកទី២ របស់អាជ្ញាប័ណ្ណនេះ ។